# មេរៀនទី ១០៦៖ ទេវតាបានបង្ហាញខ្លួននៅមុខយ៉ូសែប

## អេសាយ ៧៖១៣-១៤, ម៉ាថាយ ១៖១៨-២៥

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/623e3Ym7qwg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/gOOf3nbBuko

**គោលបំណង៖** ផែនការរបស់ព្រះគឺល្អឥតខ្ចោះ។

**ខគម្ពីរចងចាំ៖ យេរេមា ២៩៖១១** *"ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្ដីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្ដីសង្ឃឹម។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ជួងណូអែល https://youtu.be/ZoeNhcK7ROo

២. អបអរណូអែល https://youtu.be/byWKhgcbMk8

៣. ព្រះចាត់បុត្រា https://youtu.be/eDsWfEtrnS0

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ស្ដាប់តាមសំលេង»

សម្ភារៈដែលត្រូវការ៖ ម៉ាស ឬក្រមា ឧបសគ្គ( កៅអី, សៀវភៅ, ដុំថ្ម ។ល។)

១. ដាក់ពង្រាយឧបសគ្គទាំងអស់នៅកណ្ដាលថ្នាក់រៀន។

២. ចែកកុមារជា ២ក្រុម

៣. ជ្រើសកុមារម្នាក់មកពីក្រុមទាំង ២ ហើយប្រើក្រមា ឬម៉ាស់បិទភ្នែកពួកគេ។



៤. គ្រូនឹងផ្ដល់ការណែនាំដល់កុមារ ឲ្យឆ្លងកាត់ឧបសគ្គ ដោយដើររំលង ឬដើរវាងឧបសគ្គទាំងនោះ ដើម្បីឲ្យពួកគេដើរទៅដល់ផ្នែកម្ខាងទៀតនៃថ្នាក់រៀន។

៥. វាគឺពិតជាមានសារៈសំខាន់ណាស់ក្នុងការស្ដាប់តាមការណែនាំរបស់គ្រូក្នុងការលេងល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវតែដើរតាមការណែនាំរបស់ព្រះ ពីព្រោះទ្រង់តែងតែនិយាយ និងចែករំលែកមកកាន់ពួកយើង ពីផែនការដ៏អស្ចារ្យរបស់ទ្រង់សម្រាប់ពួកយើង។

### ៤. ការណែនាំមេរៀន

តើអ្នកមានគម្រោងអ្វីសម្រាប់សប្ដាហ៍ក្រោយ? តើអ្នកមានគម្រោងទៅសាលារៀនទេ? ឬតើអ្នកមានគម្រោងទៅលេងជាមួយមិត្តភក្តិ? យើងទាំងអស់គ្នាមានផែនការសម្រាប់ថ្ងៃស្អែក និងសម្រាប់អនាគតរបស់យើង។ ព្រះក៏មានផែនការដ៏អស្ចារ្យផងដែរ។ ពីព្រោះព្រះគឺគ្រប់ល័ក្ខ ផែនការរបស់ទ្រង់គឺល្អឥតខ្ចោះ។ ព្រះមានផែនការដ៏ល្អឥតខ្ចោះសម្រាប់បញ្ជូនព្រះយេស៊ូវមករកយើង។ ផែនការរបស់ព្រះមើលទៅដូចជាមិនល្អឥតខ្ចោះសម្រាប់មនុស្សមួយចំនួន ប៉ុន្តែផែនការទាំងអស់នោះគឺល្អឥតខ្ចោះ។ តោះទៅ

មើលថាហេតុអ្វីបានជាមនុស្សមួយចំនួនគិតថាផែនការរបស់ព្រះចម្លែក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះធំជាងអ្វីៗទាំងអស់! ពិតជាអស្ចារ្យណាស់ក្នុងការបញ្ជូនព្រះយេស៊ូវ ព្រះដ៏ធំដែលបានប្រសូតមកជាទារកតូចមួយ។ នោះគឺជាផ្នែកមួយនៃផែនការដែលហាក់ដូចជាចម្លែកសម្រាប់មនុស្សមួយចំនួន។ ប៉ុន្តែផែនការរបស់ព្រះគឺល្អឥតខ្ចោះ។ ព្រះចង់ឲ្យយើងអាចយល់ពីទ្រង់ ហើយស្រឡាញ់ទ្រង់ ហើយព្រះទ្រង់ជ្រាបថាទ្រង់ធំណាស់ ដែលវាអាចពិបាកសម្រាប់យើងក្នុងការធ្វើដូច្នោះ។ ដូច្នេះ ផ្នែកនៃផែនការរបស់ព្រះគឺកើតជាទារក ដូច្នេះយើងអាចយល់ពីទ្រង់បានកាន់តែច្បាស់។ វាហាក់ដូចជាចម្លែក ប៉ុន្តែវាជាវិធីដ៏ល្អឥតខ្ចោះសម្រាប់យើងក្នុងការយល់អំពីព្រះ។

មានរឿងមួយទៀតដែលមើលទៅចម្លែកសម្រាប់មនុស្សមួយចំនួន។ តើអ្នកបានឮព្រះយេស៊ូវត្រូវបានគេហៅថាព្រះលើព្រះ និងជាស្តេចលើស្តេចទេ? នេះមានន័យ ថាទ្រង់ជាស្តេចនៃអ្វីៗគ្រប់យ៉ាង និងគ្រប់ទីកន្លែង។ ស្តេចនឹងរស់នៅក្នុងវាំងដ៏ធំនៅក្នុងទីក្រុងដ៏អស្ចារ្យជាមួយនឹងសម្លៀកបំពាក់ និងមកុដដ៏ស្រស់ស្អាតផង។ ប៉ុន្តែព្រះយេស៊ូវមិនមានរបស់ទាំងនេះទេ។ ព្រះអង្គមិនបានប្រសូត្រនៅក្នុងទីក្រុងធំ ឬក្នុងវាំងធំទេ។ ទ្រង់មិនមានមកុដ ហើយព្រះអង្គក៏មិនមានសម្លៀកបំពាក់ស្អាតដែរ។ ព្រះអង្គប្រសូត្រនៅក្នុងទីក្រុងដ៏តូចមួយកន្លែងដូចក្រោលសត្វមួយ។ នេះជាវិធីចម្លែកណាស់សម្រាប់ស្តេច ដ៏អស្ចារ្យនេះបានប្រសូត្រមក។ ប៉ុន្តែនោះជារបៀបដែលព្រះចង់ឱ្យវាក្លាយជាបែបហ្នឹង។

បើព្រះយេស៊ូវប្រសូត្រជាស្តេចនៅក្នុងវាំងយើងពិបាកនឹងជួប ឬនិយាយជាមួយនឹងព្រះអង្គ ប៉ុន្តែផ្នែកមួយនៃផែនការរបស់ព្រះគឺយើងអាចនិយាយជាមួយទ្រង់គ្រប់ពេល។ ដោយសារព្រះយេស៊ូវបានប្រសូត្រមកតាមព្រះទ័យទ្រង់ យើងអាចចូលទៅជិតព្រះយេស៊ូវ ហើយនិយាយជាមួយទ្រង់ដោយមិនមានអារម្មណ៍ថាទ្រង់នៅឆ្ងាយពីយើងទេ។ តើព្រះមិនឆ្លាតក្នុងការរៀបចំផែនការអ្វីគ្រប់យ៉ាងល្អឥតខ្ចោះឬ?

ពេលដល់ពេលវេលាដែលផែនការដ៏ល្អឥតខ្ចោះរបស់ព្រះក្នុងការបញ្ជូនព្រះយេស៊ូវ ទ្រង់បានចាត់ទេវតាមកជួបបុរសម្នាក់ឈ្មោះយ៉ូសែប។ យ៉ូសែបនឹងរៀបការឆាប់ៗជាមួយនឹងស្ត្រីម្នាក់ឈ្មោះ ម៉ារា។ ប៉ុន្តែមានទេវតាមួយមកប្រាប់យ៉ូសែបថាម៉ារានឹងមានកូន។ នេះជាដំណឹងអាក្រក់ព្រោះវាមិនមែនជាកូនរបស់យ៉ូសែប។ ទេវតាក៏បានប្រាប់គាត់ថា ទារកនោះនឹងជាព្រះអង្គសង្គ្រោះ ហើយគាត់ត្រូវដាក់ឈ្មោះទារកនោះថា យេស៊ូវ។

យ៉ូសែប មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះផែនការរបស់ព្រះ ប៉ុន្តែគាត់ស្រឡាញ់ព្រះ ហើយគាត់ជឿជាក់លើព្រះ។ យ៉ូសែបបានសម្រេចចិត្តថាគាត់នឹងគោរពតាមព្រះ ហើយទុកចិត្តថាផែនការរបស់ព្រះគឺល្អឥតខ្ចោះ ទោះបីជាគាត់មិនយល់ពីវាក៏ដោយ។

ព្រះចង់ឲ្យយ៉ូសែបដឹងអំពីផែនការដ៏ល្អឥតខ្ចោះរបស់ទ្រង់ក្នុងការបញ្ជូនព្រះយេស៊ូវឲ្យមក ដូច្នេះព្រះបានបញ្ជូនទេវតាមកជួបយ៉ូសែប។ ហើយព្រះចង់ឱ្យយើងទាំងអស់គ្នាដឹងអំពីព្រះយេស៊ូវ។ ព្រះក៏ចង់ឱ្យយើងជឿជាក់លើទ្រង់ ហើយជឿជាក់លើផែនការដ៏ល្អឥតខ្ចោះរបស់ទ្រង់សម្រាប់យើង ទោះបីជាយើងមិនយល់ច្បាស់ក៏ដោយ! សូមចាំថា ផែនការរបស់ព្រះសម្រាប់យើងគឺល្អឥតខ្ចោះជានិច្ច!

## ៦. សំនួរពិភាក្សា

១. តើមានអ្វីចម្លែកចំពោះផែនការរបស់ព្រះក្នុងការបញ្ជូនព្រះយេស៊ូវឲ្យមក?
*(ព្រះបញ្ជូនព្រះយេស៊ូវឲ្យ មកប្រសូត្រជាទារក ហើយមិនបានគង់នៅក្នុងវាំងដូចជាស្តេចផងទៃទៀតទេ)*
២. ហេតុអ្វីបានជាព្រះមានគម្រោងធ្វើដូច្នេះ?

*(ដើម្បីឲ្យយើងអាចចូលទៅជិតព្រះយេស៊ូវបានងាយស្រួល ហើយស្គាល់ព្រះកាន់តែច្បាស់)*
៣. តើអ្វីជាការពិបាកសម្រាប់យ៉ូសែបក្នុងការទទួលយក ដើម្បីស្តាប់បង្គាប់ព្រះដើម្បីរៀបការជាមួយម៉ារា?
*(នាងកំពុងមានកូនដែលមិនមែនជាកូនរបស់យ៉ូសែប)*
៤. ហេតុអ្វីបានជាយ៉ូសែបស្តាប់បង្គាប់ព្រះ ហើយរៀបការជាមួយម៉ារា?
*(ដោយសារគាត់បានដឹងថា ផែនការរបស់ព្រះគឺល្អឥតខ្ចោះ)*

**៧. ល្បែងកំសាន្ត** **«Yes and No»**

សម្ភារៈដែលត្រូវការៈ កៅអី២ ក្រដាស២សន្លឹក ដែលមួយសរសេរពាក្យថា“Yes”មួយទៀតសរសេរ




ពាក្យថា “No”

១. យើងឲ្យកុមារឈរជាជួរតែមួយ

២.ដាក់កៅអី ដែលបានសរសេរពាក្យ “yes” “No” នៅខាងមុខកុមារ។

៣.កុមារត្រូវលោតទៅតាមពាក្យដែលគ្រូស្រែក បើគ្រូស្រែកថា “No” កុមារត្រូវលោតទៅខាង “No” បើគ្រូស្រែកថា “yes”កុមារត្រូវលោតទៅពាក្យថា “yes”។ គ្រូអាចបញ្ឆោតកុមារដោយនិយាយដដែលៗ “yes” “No” ឬក៏គ្រូអាចនិយាយឲ្យញាប់ជាងមុន។

៤. នៅពេលដែលកុមារលោតខុសនោះពួកគេត្រូវឈរនៅម្ខាង។

៥. លេងល្បែងនេះរហូតនៅសល់កុមារតែម្នាក់ដែលជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ការស្តាប់និងដើរតាមការណែនាំពិតជាមានសារៈសំខាន់ណាស់។ ពួកយើងត្រូវតែស្តាប់ និងដើរតាមការណែនាំរបស់ព្រះ នោះយើងនឹងទទួលបាននូវអ្វីដែលព្រះបានសន្យាសម្រាប់យើង។

**៨. ខគម្ពីរចងចាំ**

**យេរេមា ២៩៖១១** *“ដ្បិតព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា អញស្គាល់សេចក្តីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឲ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម។”*

**៩. ហត្ថកម្ម**




សម្ភារៈដែលត្រូវការៈ ក្រដាសស កន្ត្រៃ កាវ ប៊ិច

១. ឱ្យកុមារគូរដៃរបស់ពួកគេលើក្រដាសស ក៏ដូចជាគូរ ត្រីកោណ បន្ទាប់មកកាត់វាចេញ។

២. ឲ្យកុមារគូរមុខទេវតា ហើយកាត់វាចេញ។

៣. យកកាវបិតដៃទាំងពីរនៅពីក្រោយរូបត្រីកោណហើយ បន្ទាប់មកបិតមុខរបស់ទេវតា។

៤. នៅលើរូបកាយទេវតាសូមឲ្យកុមារសរសេរថា «ផែនការរបស់ព្រះគឺល្អឥតខ្ចោះ»។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**

ព្រះយេស៊ូវបានលើកទឹកចិត្តអ្នកដើរតាមទ្រង់ឲ្យទុកចិត្តព្រះ ដោយសារទ្រង់ដឹងថា ព្រះនឹងមើលថែពួកគេ—ដូចទ្រង់បានមើលថែយ៉ូសែប ម៉ារា និងព្រះយេស៊ូវដែរ។ គោលបំណងរបស់ព្រះសម្រាប់យើងគឺស្រស់ស្អាត។ ប្រហែលជាមានអ្វីមួយនៅក្នុងផែនការរបស់ព្រះអង្គមិនសមហេតុផលសម្រាប់ អ្នកនៅពេលនេះទេ។ សុំជំនួយ នោះព្រះនឹងបង្ហាញអ្នកទាន់ពេល ថាតើផែនការរបស់ទ្រង់ល្អឥតខ្ចោះសម្រាប់អ្នកយ៉ាងណា។ កុំខ្លាចព្រះនឹងមិនធ្វើឱ្យអ្នកខកចិត្តឡើយ។ អ្នកតែងតែអាចពឹងផ្អែកលើព្រះបានជានិច្ច។